# កុំឲ្យទំរ

បទពាក្យ៨

គេដាក់ហ្វុងខ្មែរខ្ញុំចេញហ្វុងខ្មែរ បើគេមិនកែខ្ញុំថែអ៊ីចឹង
ត្រង់ខុសត្រង់ត្រូវខ្ញុំមិនខ្ចីដឹង ខ្ញុំគិតតែប្រឹងឲ្យត្រូវចិត្តគេ។
បើគេថាខុសគេលុបគេប្តូរ ដកចេញដាក់ចូលលើកត្រង់រុញទេ
ខ្ញុំធ្វើតាមបានមិនស្តីខឹងជេរ ព្រោះជាសិទ្ធិគេដែលជាម្ចាស់ខ្ញុំ។
ទោះចិត្តមិនពេញក៏មិនតវ៉ា មិនព្រមតបថានាំកើតទុក្ខធំ
ខ្លាចគេទើសចិត្តគេចោលមួយដុំ ឈប់រាប់អានខ្ញុំលែងឲ្យការធ្វើ។
បើគេចង់ប្រើគេរត់រកជាង មកពុះរូបរាងដោះគ្រឿងរុសរើ
ឲ្យជាងកាត់ផ្លាស់ឲ្យខ្ញុំរង្គើ បើកខួរងងើរស្តាប់គេដូចដើម។
បើខ្ញុំនៅដឹងប្រឹងប្រឆាំងទៀត ក្រោយផ្ទុះកន្លៀតបោះបាលសន្សៀម
ឲ្យច្រែះព្រួតស៊ីខូចគ្រើមរអើម ហើយស្តីចុងដើមថាខ្ញុំអត់ខ្មេះ។
គេហូតក្រដាស់មកទិញមួយថ្មី មិនទាន់ដឹងអ្វីរោគនោះមិនចេះ
ដឹងតែធ្វើតាមឲ្យតែគេកេះ នោះទើបពិសេសពេញចិត្តមេនាយ។

ភ្នំពេញ ១៣មិថុនា ២០០៦
សួយ ឡូត